**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
លេខៈ០១៨ /០៨ កហ អ.គ.គ

**កំណត់ហេតុ ស្តីពី**
**សិក្ខាសាលាពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ**
**កំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល នៅខេត្តបាត់ដំបង**

ឆ្នាំពីរពាន់ប្រាំបី ខែមេសា ថ្ងៃទី សាមសិប វេលាម៉ោងប្រាំបី នៅសាលប្រជុំសាលាខេត្តបាត់ដំបង មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងមានការចូលរួមពីឯកឧត្តម សៀង ស៊ុតថង អភិបាលរងខេត្តបាត់ដំបង ឯកឧត្តម អ៊ូ ឡុងឌី អភិបាលរងខេត្តបន្ទាយមានជ័យ ព្រមទាំងឯកឧត្តម អៀង វុធ អភិបាលរងក្រុងប៉ៃលិន ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែ ទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម សៀង ស៊ុតថង អភិបាលរងខេត្តបាត់ដំបង បានធ្វើការស្វាគមន៍ចំពោះគណៈ អធិបតី និងថ្លែងអំណរគុណឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល ដើម្បីផ្តល់នូវព័ត៌មាន និងចែករំលែកនូវបទពិសោធន៍ផ្សេងៗ ដល់មន្ត្រីរបស់ស្ថាប័នជំនាញនានា នៅតាមបណ្តាខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតអំពីការកែទម្រង់ច្បាប់ និងតុលាការ ។ ឯកឧត្តម មានការចាប់អារម្មណ៍ផងដែរថា វិស័យកំណែទម្រង់ច្បាប់ និងតុលាការនេះជាអាទិភាពមួយដ៏ចាំបាច់បំផុតរបស់ រាជរដ្ឋាភិបាលកម្ពុជា យើងដែលត្រូវតែធ្វើជាបន្ទាន់ ហើយឯកឧត្តមសង្ឃឹមថា សហការីមកពីមន្ទីរស្ថាប័នជំនាញផ្សេងៗជុំវិញខេត្តបាត់ដំបង នឹងចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាក្នុងអង្គសិក្ខាសាលានេះ ។ ជាមួយគ្នានោះផងដែរ ឯកឧត្តមបានបង្ហាញនូវការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តការងារនេះកំណែទម្រង់របស់

ខេត្តបាត់ដំបង ហើយឯកឧត្តមសង្ឃឹមថា សកម្មភាពកំណែទម្រង់របស់ខេត្តបាត់ដំបង នេះនឹងអាចដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការរបស់រាជរដ្ឋាភិបាលទាំងស្រុងដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការអោយកាន់តែខ្លាំងឡើងថែមទៀត ។

បន្ទាប់ពីសន្ទរកថារបស់ឯកឧត្តមអភិបាលខេត្តកំពង់ចាម ឯកឧត្តម អ៊ូ ឡង់ឌី អភិបាលរងខេត្តបន្ទាយមានជ័យ បានធ្វើបទអន្តរាគមន៍ ស្តីអំពីគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលសម្រាប់កំណែទម្រង់ច្បាប់ និងតុលាការ ។

ជាបឋមឯកឧត្តមបានថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះភ្ញៀវកិត្តិយស និងថ្នាក់ដឹកនាំជុំវិញខេត្តទាំងបី ដែលបានមកចូលរួមពិភាក្សាផ្លាស់ប្តូរយោបល់ និងចែករំលែកទស្សនៈ និងបទពិសោធន៍គ្នានាថ្ងៃនោះ ។ ឯកឧត្តមបាន មានប្រសាសន៍ថា កំណែទម្រង់៤ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទីបីនៃរដ្ឋសភា គឺមានកំណែទម្រង់កម្លាំងប្រដាប់អាវុធ កំណែទម្រង់ច្បាប់ និងតុលាការ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងកំណែទម្រង់រដ្ឋបាលសាធារណៈ ។ ជាមួយគ្នានោះឯកឧត្តមបានជម្រាបជូនថា យើងធ្វើកំណែទម្រង់ទាំងបួនយ៉ាងនេះ ក្នុងគោលដៅរួមមួយគឺអភិបាលកិច្ចល្អ ហើយឯកឧត្តមបានបញ្ជាក់ទៀតថា បើរាជរដ្ឋាភិបាលមានគោលនយោបាយជាតិប្រកបដោយអភិបាលកិច្ចល្អ ប្រទេសជាតិយើងនឹងមានការ អភិវឌ្ឍន៍រីកចំរើនទៅមុខយ៉ាងប្រាកដ ។

ជាបន្ទាប់ ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើការបង្ហាញជូនអង្គសិក្ខាសាលា អំពីដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានបង្កើតឡើងនៅថ្ងៃ ទី ២០ ខែមិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម ឌិត មន្ទី ប្រធានតុលាការកំពូលជាសហប្រធាន ។ ឯកឧត្តមបានបង្ហាញជូនអង្គប្រជុំអំពីអង្គភាព ផ្សេងៗរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលរួមមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) បង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ និងអង្គភាពគ្រប់គ្រងគម្រោង ( PMU ) បង្កើតឡើងនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ឯកឧត្តមបានជម្រាបជូនអង្គសិក្ខាសាលាអំពីសារសំខាន់ និងគោលដៅនៃកំណែទម្រង់ច្បាប់ និងតុលាការ គឺការបង្កើតនូវវិស័យច្បាប់ និងតុលាការមួយដែលអាចជឿទុកចិត្តបាន និងមានស្ថេរភាពសម្រាប់ទ្រទ្រង់គោលការណ៍សិទ្ធិរបស់បុគ្គល ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋនៅក្នុងលិទ្ធិប្រជាធិបតេយ្យសេរី តាមរយៈការលើកស្ទួយនូវការរីកចំរើនសេដ្ឋកិច្ចនាំមុខដោយវិស័យឯកជន ។ ឯកឧត្តមបានបញ្ជាក់ថា ការកែទម្រង់ច្បាប់ និងការកែទម្រង់តុលាការទាំងពីរនេះ មិនអាចដាច់ពីគ្នាបានទេ ត្រូវតែមានការពាក់ព័ន្ធគ្នាទៅវិញទៅមក ។ ឆ្លៀតឱកាសនោះដែរ ឯកឧត្តមបានជម្រាបជូនអង្គ សិក្ខាសាលាអំពីការរៀបចំតុលាការគំរូចំនួន០៤ នៅតុលាការក្រុងភ្នំពេញ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តបន្ទាយមានជ័យ ។

លោក នូវ យ៉ារ័ត្ន ប្រធានសាលាដំបូងនៃខេត្តបាត់ដំបង បានធ្វើបាយការណ៍អំពីការងារអនុវត្ត កំណែទម្រង់ច្បាប់ និងតុលាការរបស់តុលាការខេត្តបាត់ដំបង ។

លោកបានមានប្រសាសន៍ថា ចាប់តាំងពីរាជរដ្ឋាភិបាលដែលមានសម្តេចតេជោ ហ៊ុន សែន ជាប្រមុខបានដាក់ចេញនូវគោលនយោបាយកំណែទម្រង់ច្បាប់ និងតុលាការ អោយអនុវត្តមកប្រទេសកម្ពុជា យើងបានទទួលនូវក្រមចំនួនបីសំខាន់ៗសម្រាប់អោយតុលាការប្រើប្រាស់គឺ ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិវិធី ព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី ។ តុលាការបាត់ដំបងក៏ដូចជាតុលាការទូទាំងប្រទេសដែរ បានអនុវត្តនូវ គោលការណ៍ផ្លាស់ប្តូរចៅក្រមពីតុលាការមួយទៅតុលាការមួយតាមអាណត្តិរបស់ខ្លួន ។ សម្រាប់ចៅក្រម និង ព្រះរាជអាជ្ញា យើងមានក្រមសីលធម៌របស់ចៅក្រម ដែលជាមាគ៌ាសម្រាប់ចៅក្រមទាំងអស់ប្រតិបត្តិ ទាំងការរស់នៅក្នុងសង្គមក៏ដូចជាអនុវត្តវិជ្ជាជីវៈរបស់ខ្លួន ។ សាលាដំបូងខេត្តបាត់ដំបង បានទទួលនូវប្រាក់ពីរដ្ឋាភិបាល ដើម្បីជុសជុលអាគារសាលាដំបូងទាំងមូល និងបានសាងសង់អាគារសវនាការថ្មីមួយបន្ថែមទៀត និងបំពាក់ឧបករណ៍ កាមេរ៉ា វីឌីអូ សម្រាប់ធ្វើសវនាការបទល្មើសពាក់ព័ន្ធទៅលើស្ត្រី និងកុមារ ។ ចៅក្រម ដែលធ្លាប់បំពេញការងារសាលាដំបូងខេត្តបាត់ដំបង ត្រូវបានផ្លាស់ប្តូរបំពេញការងារនៅខេត្តផ្សេង ចំណែកចៅក្រមនៅតាមបណ្តាខេត្តផ្សេងក៏ត្រូវបានផ្លាស់ប្តូរមកបំពេញការងារនៅខេត្តបាត់ដំបងនេះដែរ។ ទាំងចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី សុទ្ធសឹងតែបានទទួលការបណ្តុះបណ្តាលបន្តទាំងអស់ចំពោះច្បាប់ថ្មីៗរដ្ឋសភាបានអនុម័ត ។ ការបែងចែកសំណុំរឿងដោយស្វ័យប្រវត្តិទៅតាមច្បាប់កំណត់មិនត្រឹមតែទទួលបាននូវយុត្តិធម៌ សម្រាប់តុលាការទេ ថែមទាំងផ្តល់យុត្តិធម៌ដល់គូក្តីដែលមកពឹងពាក់តុលាការដោះស្រាយជម្លោះរបស់ខ្លួនទៀតផង ។

ទន្ទឹមនឹងការរីកចំរើនលើវិស័យកំណែទម្រង់ច្បាប់ និងតុលាការនេះ ចៅក្រម ព្រះរាជអាជ្ញា ក៏មានបញ្ហា លំបាកដែរ មានជាអាទិ៍ ៖

- ការយល់ដឹងខុសគ្នាចំពោះអត្ថន័យនៃពាក្យច្បាប់ ធ្វើអោយមានទំនាស់កើតឡើងខាងទស្សនៈ
- ការជំនុំជំរះបទល្មើសឧក្រិដ្ឋ រឿងពាក់ព័ន្ធបទល្មើសលើស្ត្រី និងកុមារ ច្បាប់តម្រូវអោយមានការកាត់ក្តីជាក្រុមប្រឹក្សា និងតម្រូវអោយមានវត្តមានមេធាវីការពារក្តីក្នុងរឿងនេះជាដាច់ខាត ដែលនាំអោយមានបញ្ហាខ្វះខាតមេធាវី ក្នុងពេលធ្វើសវនាការ បញ្ហាខ្វះចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជី ( បច្ចុប្បន្ននេះទាំងចៅក្រម និងព្រះរាជអាជ្ញាមានចំនួន ២១នាក់ ប៉ុន្តែសំណុំរឿង មានច្រើនលើសលប់ ចំនួន២តំបន់ គឺ ខេត្តបាត់ដំបង និងក្រុង ប៉ៃលិន ) ។
- បញ្ហាលំបាកមួយទៀត គឺការបញ្ជូនដីកាកោះ ធ្វើអោយតុលាការអនុវត្តការងារមានការយឺតយ៉ាវ ឬទៅមិនដល់ ។
- ការផ្លាស់ប្តូរចៅក្រមពីតុលាការមួយទៅមួយ ធ្វើអោយមានការលំបាកប៉ះពាល់ដល់ជីវភាពគ្រួសាររបស់ចៅក្រមទាំងអស់ ។ព្រោះត្រូវការចំណាយថ្មី លើការស្នាក់នៅ និងការហូប ចុក ។

ជាចុងក្រោយលោកបានសំណូមពរអោយខាងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បន្តការបណ្តុះបណ្តាលចៅក្រម និងក្រឡាបញ្ជី ធ្វើយ៉ាងណាអោយតុលាការខេត្តបាត់ដំបងអាចទទួលបាននូវចៅក្រម និងក្រឡាបញ្ជីបន្ថែមទៀត គ្រប់ចំនួនតាមសេចក្តីត្រូវការដើម្បីអនុវត្តការងាររបស់ខ្លួនអោយបានល្អប្រសើរជាងមុន ។

លោក អាំង មាលតី ប្រធានសាលាដំបូង ខេត្តបន្ទាយមានជ័យ បានមានប្រសាសន៍ថា គោលដៅនៃកំណែទម្រង់ គឺបំរើផលប្រយោជន៍ប្រជាពលរដ្ឋ ហើយលោកបានចោទសួរថា តើវិធីណាដែលអាចវាស់វែងថា មានយុត្តិធម៌ ។ លោកបានបកស្រាយថាភាពយុត្តិធម៌នេះ គឺត្រូវទទួលបានដល់សង្គម ហើយទទួលបានដល់កូនក្តីផង និងអាស្រ័យលើច្បាប់ផងដែរ ។

ជាមួយគ្នានោះលោកប្រធានតុលាការខេត្តបន្ទាយមានជ័យក៏ជម្រាបដល់អង្គសិក្ខាសាលាផងដែរ អំពី គោលការណ៍នៃការផ្តល់យុត្តិធម៌ ៖

១- ត្រូវមានចៅក្រម (ចៅក្រមអាសនៈ និងចៅក្រមអយ្យការ) គ្រប់គ្រាន់

២- ត្រូវមានកិច្ចសហការពីស្ថាប័នជំនាញពាក់ព័ន្ធ ជាពិសេសអ្នកធ្វើកោសល្យវិច័យ ប្រសិនបើអ្នកធ្វើកោសល្យវិច័យអយុត្តិធម៌នោះ ចៅក្រមក៏កាត់ក្តីទៅតាមនោះដែរ

៣- ត្រូវមានឯករាជ្យភាព ៖ នគរបាលយុត្តិធម៌ជាអ្នកផ្សំគ្រឿងដំបូងបង្ហស់អោយតុលាការ ការចូលរួមរបស់មន្ត្រីយុត្តិធម៌ជារឿងសំខាន់ណាស់ក្នុងការប្រមូលភស្តុតាងថ្មី និងឯកសារពាក់ព័ន្ធ បើការបំពេញការងាររបស់មន្ត្រីនគរបាលយុត្តិធម៌មានកំរិតខ្ពស់នោះ ការកាត់ក្តីក៏មានកំរិតខ្ពស់ទៅតាមនោះដែរ

៤-កម្លាំងសាធារណៈជាកម្លាំងបូកផ្សំ និងកិច្ចការរបស់ចៅក្រមដែរ ចំពោះមេធាវីក៏ជាកត្តារួមផ្សំក្នុងការរកយុត្តិធម៌ផងដែរ ពេលខ្លះដល់ពេលធ្វើសវនាការ លោកមេធាវីសុំលើកពេលជាហេតុធ្វើអោយកូនក្តីស្រែកថា អយុត្តិធម៌ធ្វើអោយខាតពេលវេលាធ្វើអោយធុញទ្រាន់ទាំងនេះនាំអោយមានការ ចោទប្រកាន់ថាចៅក្រម មិនយុត្តិធម៌ ដូច្នេះដើម្បីអោយមានយុត្តិធម៌យ៉ាងពិតប្រាកដ ត្រូវមានកត្តា ធនធានមនុស្ស សម្ភារៈ មធ្យោបាយ សីលធម៌ ( ក្រមសីលធម៌) និងឯករាជ្យភាព ។

លោកប្រធានតុលាការបានលើកឡើងអំពីការផ្លាស់ប្តូរ ចៅក្រមទៅតាមវេនរបស់ក្រសួងយុត្តិធម៌ថា ជាហេតុបណ្តាលអោយប៉ះពាល់ដល់សតិអារម្មណ៍ របស់ចៅក្រមផងដែរ ព្រោះវាទាក់ទងទៅនឹងជីវភាពប្រចាំថ្ងៃ ការហូបចុកការស្នាក់នៅដាច់ពីគ្រួសារជាដើម ។ បញ្ហាមួយទៀត គឺខ្វះបន្ទប់ធ្វើការសម្រាប់ចៅក្រម ដោយបន្ទប់ធ្វើការមានលក្ខណៈតូចចង្អៀត ដូចនេះចៅក្រមមិនអាចធ្វើការកើតទេ ។ បញ្ហាដ៏ចម្បងមួយទៀតនោះគឺ បញ្ហាខ្វះខាតក្នុងការគ្រប់គ្រង រដ្ឋបាលតុលាការ មិនទាន់មាននីតិវិធីឯកភាពគ្នា ។

លោកបានសង្កត់ធ្ងន់ថា ដើម្បីអោយប្រធានតុលាការមានសិទ្ធិគ្រប់គ្រងសំណុំរឿង គ្រប់គ្រងរដ្ឋបាលតុលាការ និងចៅក្រមនីមួយៗ លុះត្រាតែប្រធានតុលាការជាប្រធានក្រុមប្រឹក្សាវិន័យ បើមិន

ដូច្នោះទេ ចៅក្រម មិនខ្លាចប្រធានសាលាដំបូងទេ ។ ជាចុងក្រោយលោកក៏បានអំពាវនាវសុំអោយលោក Ben ដែលជាទីប្រឹក្សា គម្រោង CCJAP ជួយលើកគម្រោងបំពេញនូវការ ខ្វះខាតរបស់សាលាដំបូងខេត្តបន្ទាយមានជ័យផង ។

ឯកឧត្តម ប៉ែន ប៊ុនឈា នាយករងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទបង្ហាញ អំពីតារាងស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការនៅកម្ពុជា ។ ឯកឧត្តមធ្វើការ ពន្យល់បង្ហាញតាមរយៈការចែកជូនឯកសារ និងតាមការបញ្ចាំងស្លាយ ។

ឯកឧត្តម សៀង ស៊ិតថង បានមានយោបល់អំពីការផ្សព្វផ្សាយច្បាប់ និងលើកសំណូមពរដល់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សូមចាត់អោយមានអង្គភាពធ្វើការផ្សព្វផ្សាយច្បាប់អោយបានដល់ប្រជាពលរដ្ឋ ព្រោះច្បាប់ថ្មីៗចេញច្រើនណាស់ ហើយចំពោះអង្គការដែលទទួលបន្ទុកធ្វើការផ្សព្វផ្សាយច្បាប់ ស្នើសុំកំណត់ឯកសារច្បាប់អោយបានត្រឹមត្រូវ ថាតើឯកសារណាមួយដែលត្រូវយកមកផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ជាសេចក្តីព្រាងច្បាប់ ឬផ្នែកណាមួយនៃច្បាប់ ។ ម្យ៉ាងវិញទៀត ទាក់ទងទៅនឹងយុទ្ធសាស្ត្រទី៦ គឺយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឯកឧត្តមបានជម្រាបថា គណៈកម្មាការដោះស្រាយវិវាទដីធ្លីគ្មានប្រសិទ្ធភាពទេ បើនិយាយអោយចំទៅ គឺគណៈកម្មាការសុរិយោដីមិនបានធ្វើការនោះតែម្តង ជាហេតុធ្វើអោយរឿងដីធ្លី កកស្ទះច្រើនឡើងៗ ដូច្នេះឯកឧត្តមបានស្នើសុំអោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជួយបង្កើតយន្តការបន្ថែមទៀត ។ ទាក់ទងនឹងបញ្ហាមេឃុំនៅទីនោះដែរ ឯកឧត្តមបានស្នើសុំអោយមានមន្ត្រីសេវាកម្មម្នាក់នៅថ្នាក់ឃុំ ដើម្បីជួយថ្នាក់ឃុំ ឬមេឃុំ ដើម្បីងាយស្រួលក្នុងការណែនាំពន្យល់ជូនប្រជាពលរដ្ឋ ។

លោក ហាម មុន្នី មេធាវីខេត្តបាត់ដំបង បានធ្វើចំណាប់អារម្មណ៍ទៅលើ យុទ្ធសាស្ត្រទី ២ គឺធ្វើទំនើបកម្ម ក្របខណ្ឌច្បាប់ទាក់ទងនឹងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ដែលពាក់ព័ន្ធនឹងអំពើអយុត្តិធម៌ គឺបណ្តាលមកពីគ្មាន ច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រមនេះតែម្តង ដូច្នេះលោកបានសំណូមពរអោយច្បាប់នេះចេញអោយបានឆាប់ ដើម្បីគ្រប់គ្រងចៅក្រមបំបាត់អំពើពុករលួយ និងជាទំនុកចិត្តដល់ប្រជាពលរដ្ឋ ។

លោក សួស សំអាត ចៅក្រមខេត្តបន្ទាយមានជ័យ បានចោទជាសំណួរថា តើតុលាការគំរូឈរលើចំណុចអ្វីខ្លះ ? ហើយលោកបានសំណូមពរអោយតំណាងក្រុមប្រឹក្សាកំណត់អោយច្បាស់ ។

ឆ្លើយតបនឹងសំណួរទាំងអស់ខាងលើឯកឧត្តម សួង លាងហៃ បានមានប្រសាសន៍ថា ទាក់ទងនឹងការផ្សព្វផ្សាយច្បាប់ក្នុងការអនុវត្តសព្វថ្ងៃ ក្រសួងដែលជាអ្នករៀបចំផ្តួចផ្តើមធ្វើច្បាប់ ជាអ្នកទទួលបន្ទុកផ្សព្វផ្សាយច្បាប់នោះ បន្ថែមលើភារកិច្ចជាប្រចាំរបស់អគ្គនាយកដ្ឋានរាជកិច្ច នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

ចំណែកឯច្បាប់ដែលត្រូវផ្សព្វផ្សាយវិញ គឺច្បាប់ដែលបានអនុម័តរួច និងមានឡាយព្រះហស្តលេខារបស់ ព្រះមហាក្សត្រប្រកាស់អោយប្រើ ។ ចំពោះប្រសិទ្ធិភាពនៃការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ឯកឧត្តម ប្រធានបានលើកបង្ហាញជូនអង្គសិក្ខាសាលាអំពីកិច្ចខិតខំប្រឹងប្រែងមួយចំនួនរបស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មានជាអាទិ៍ ៖ ការបណ្តុះបណ្តាលមន្ត្រីមូលដ្ឋានអោយយល់ដឹងអំពីច្បាប់ ការបង្កើតមណ្ឌលសេវាកម្មយុត្តិធម៌ ថ្នាក់ស្រុកជាដើមតាមរយៈគម្រោង A2J សហការជាមួយ UNDP។

ទាក់ទិននឹងសំណួមពរលោក ហម មុន្នី អំពីច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ឯកឧត្តមប្រធានបានបញ្ជាក់ថា ច្បាប់នេះបានព្រាងចប់អស់ហើយ ហើយក៏បានពិភាក្សារួចម្តងដែរ នៅក្នុងក្រុមប្រឹក្សាអ្នកច្បាប់ទីស្តីការគណៈរដ្ឋមន្ត្រីនៅដើមអាណត្តិក្រោយច្បាប់នេះនឹងត្រូវបានអនុម័ត ។

ចំពោះសំណួររបស់លោក សួស សំអាត ចៅក្រមខេត្តបន្ទាយមានជ័យ ឯកឧត្តមប្រធានបានឆ្លើយបំភ្លឺថា ក្នុងការបង្កើតតុលាការគំរូ យោងទៅតាមលទ្ធភាពថវិកា ក្រុមការងារជាន់ខ្ពស់នៃគម្រោងតុលាការគំរូបាន សម្រេចជ្រើសរើសតុលាការចំនួនបួនដែលមានមូលដ្ឋានសំភារៈខ្លះហើយនោះ ធ្វើជាតុលាការគំរូក្នុងការអនុវត្តច្បាប់ ដែលចូលជាធរមានទៅតាមស្តង់ដារអន្តរជាតិ ។ សព្វថ្ងៃនេះមានការបង្កើតក្រុមការងារសម្រាប់រៀបចំ ស្តង់ដារតុលាការគំរូនេះ និងកំពុងសិក្សារៀបចំសំណួរចម្លើយ ដើម្បីឈានទៅធ្វើផែនការការងារសម្រាប់អនុវត្ត ស្តង់ដារ ដែលបានកំណត់សម្រាប់តុលាការគំរូនីមួយៗ ។

លោក អាំង មាលតី ប្រធានតុលការខេត្តបន្ទាយមានជ័យ ឆ្លើយតបទៅនឹងលោកចៅក្រម សួស សាម៉េត សន្យាថា ពេលត្រឡប់ទៅតុលាការវិញ នឹងធ្វើការបកស្រាយពន្យល់បំភ្លឺ ចៅក្រមតុលាការខេត្តអោយបានយល់ច្បាស់អំពីគោលការណ៍នៃតុលាការគំរូ ។

លោក កែវ សាម៉េត ប្រធានសហគមន៍មូលដ្ឋានព្រំដែន នៅក្រុងប៉ៃលិន បានស្នើសុំអោយបង្កើតសាលាដំបូងនៅក្រុងប៉ៃលិន និងអោយរៀបចំការិយាល័យខេត្តសម្រាប់ NGO's ធ្វើទំនាក់ទំនងព្រមទាំងសុំកុំ អោយគិតគូពីបញ្ហាខ្វះខាតរបស់តុលាការច្រើនពេក ក្នុងពេលដែលប្រជាពលរដ្ឋមានការខ្វះខាតច្រើនជាងនោះទៅទៀត ។

លោកប្រធានមន្ទីរនគរូបនីយកម្មដែនដី និងសំណង់ បានមានសំណូមបី គឺ ៖

1- ពាក់ព័ន្ធនឹងការចុះអនុវត្តសាលដីកាលោកបានស្នើសុំអោយស្ថាប័នសាលាដំបូងខេត្តជូនដំណឹងយ៉ាងហោច ណាស់ក៏បានមួយថ្ងៃមុនដែរ ជាពិសេសពាក់ព័ន្ធ និងរឿងដីធ្លី ។

2- ទាក់ទងនឹងការវាយតំលៃការលក់ទិញដី គួរធ្វើទំនាក់ទំនងទៅខាងពន្ធដារ ព្រោះមិនមែនជារឿងសុរិយោដីខេត្តទេ

3- ស្នើសុំអោយមានភាគីដើម និងចុងបណ្តឹងធ្វើការសហការគ្នាដើម្បីងាយស្រួលខាងមន្ទីរធ្វើការវាស់វែង ។

ទាក់ទងនឹងរឿងវិវាទដីធ្លី ហើយសាលក្រមបានចេញជាស្ថាពរ អោយមានកម្លាំងសមត្ថកិច្ចចុះធ្វើការវាស់វែង ប៉ុន្តែដល់ពេលវាស់វែងសេចក្តីជូនដំណឹងរបស់ទីស្តីការគណៈរដ្ឋមន្ត្រី បានប្រគល់អោយអ្នកផ្សេងធ្វើការនេះវិញ ដូច្នេះលោកបានសួរថា តើអោយអាជ្ញាធរជំនាញណាមួយទៅធ្វើការវាស់វែងអោយប្រាកដនោះ ?

លោក នៅ យ៉ារ័ត្ន បានស្នើជាយោបល់ដល់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌មេត្តាជួយលើកជាយោបល់អោយក្រុមប្រឹក្សាធ្វើសេចក្តីណែនាំមួយទូទាំងប្រទេស ថាតើប្រធានតុលាការមានសិទ្ធិគ្រប់គ្រងតុលាការក្នុងកំរិតណា ?

លោក អាំង មាលតី ជាកិច្ចឆ្លើយតបនឹងលោក កែវ សាម៉េត បានមានប្រសាសន៍ថា លោកនឹងបើកកិច្ចប្រជុំមួយរវាងមន្ទីររៀបចំនគរូបនីយកម្ម និងសំណង់ និងពន្ធដារ ដើម្បីពិភាក្សាពាក់ព័ន្ធនឹងតុលាការ ។

ចំពោះបញ្ហាចុះវាស់វែងដីទំនាស់នេះ លោកបានជម្រាបថា នៅពេលដែលមន្ទីរជំនាញធ្វើការវាស់វែង ភាគីម្ខាងទៀតដែលមិនចូលរួមនោះ មានបញ្ហាស្ទើរគ្រប់ខេត្តក្រុង ហេតុនេះលោកបានស្នើរសុំអោយមន្ទីរជំនាញ មេត្តាជួយពន្យល់ដល់ប្រជាពលរដ្ឋផង ព្រោះពួកគាត់តែងតែគិតថា កាលណាមន្ទីរសុរិយោដីចុះវាស់វែងហើយ ច្បាស់ជាធ្វើប្លង់អោយភាគីម្ខាងទៀតហើយ ។ លោកបានបញ្ជាក់បន្ថែមទៀតថា មន្ទីរសុរិយោដីមិនមែនជាអ្នកចេញលិខិតបញ្ជាក់ថា ភាគីណាឈ្នះ ឬ ចាញ់នោះទេ គឺមានតែតុលាការតែប៉ុណ្ណោះ ។

ចំពោះសំណួរសួរថា សេចក្តីជូនដំណឹងទីស្តីការគណៈរដ្ឋមន្ត្រី ( ស.ជ.ណ ) និងសាលក្រមរបស់តុលាការ ថាតើគួរអនុវត្តលើណាមួយ ? លោក អាំង មាលតី បានបញ្ជាក់ថា តាមផ្លូវច្បាប់គឺគេអនុវត្តតាមសាលក្រមរបស់សាលដីកា ។

ឯកឧត្តម សួង លាងហៃ បានថ្លែងអំណរគុណចំពោះការសន្យារបស់លោក អាំង មាលតី ក្នុងការប្រជុំដោះស្រាយបញ្ហាដែលលើកឡើងដោយលោកប្រធានមន្ទីររៀបចំដែនដី ក៏ដូចជាការប្រជុំពន្យល់អំពីតុលាការ គំរូដល់ចៅក្រមនៃតុលាការខេត្ត ។ ចំពោះការណែនាំពីសិទ្ធិរបស់ប្រធានតុលាការ ឯកឧត្តមប្រធានបានបញ្ជាក់ថា នេះជាផ្នែកមួយនៅក្នុងការអនុវត្តគម្រោងតុលាការគំរូ ហើយចំពោះសំណូមពរផ្សេងៗទៀត ឯកឧត្តមសន្យាថា នឹងធ្វើការកត់ត្រាជម្រាបជូនក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ។

នៅទីបញ្ចប់ឯកឧត្តមបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមអភិបាលរងខេត្ត និងឯកឧត្តម អស់លោក ដែលជាប្រធាននិងមន្ត្រីមន្ទីរជំនាញជុំវិញខេត្តទាំងបី ដែលបានចូលរួមក្នុងអង្គសិក្ខាសាលាផ្សព្វផ្សាយនាថ្ងៃនេះ និងសូមអោយប្រកបតែនឹងពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជារៀង រហូតទៅ ។

អង្គប្រជុំពិភាក្សាបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរព្រឹកនាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៨*

បានឃើញ និងឯកភាព
ប្រធានអង្គសិក្ខាសាលា

អ្នកធ្វើរបាយការណ៍

សួង លាងហៃ

សេង វ៉ាន់ដា

ស៊ុន សិរីវុធ